

សុខភាព និងជីវិត
កាន់តែប្រសើរ

# សេវាគ្រប់គ្រង និងការប្រឹក្សាព្យាបាលផ្ទាល់ខ្លួន

AIA ជាដៃគូសហការជាមួយ Teladoc Health។ ផ្តល់ជូនអ្នកនូវការគាំទ្រវេជ្ជសាស្ត្រចាប់ពីពេលព្យាបាលរហូតដល់ចប់។

aia.com.kh

# ការធានាដែលកាន់តែអស្ចារ្យសម្រាប់ ដំណើការនៃការព្យាបាលរបស់អ្នក

នៅ **AIA** ពួកយើងពិតជាដឹងថាវាលំបាកប៉ុណ្ណាក្នុងការសម្រេចចិត្តចំពោះរឿងដែលអាចនឹងផ្លាស់ប្តូរជីវិតរបស់យើងសម្រាប់ករណីព្យាបាលធ្ងន់ធ្ងរ។

ដូចនេះហើយយើងបានពង្រឹងសំណើថែទាំសុខភាពជារួមរបស់យើងអោយកាន់តែប្រសើរ ដោយចូលរួមសហការជាមួយនឹង **Teladoc Health** ដើម្បីផ្តល់ជូននូវការថែទាំវេជ្ជសាស្ត្រផ្ទាល់ខ្លួនមួយ និងការណែនាំចាប់តាំងពីពេលធ្វើរោគវិនិច្ឆ័យ ពេលព្យាបាល រហូតដល់ពេលជាសះស្បើយឡើងវិញ។

“អ្នកឯកទេសខាងជំងឺមហារីករបស់ខ្ញុំបានណែនាំការព្យាបាលភាពស៊ាំមកខ្ញុំ។ តើនេះគឺការព្យាបាលដែលល្អបំផុតសម្រាប់ខ្ញុំហើយមែនទេ? តើមានជម្រើសផ្សេងទៀតដែរឬទេ?”



**ការពិនិត្យយ៉ាងលម្អិតដោយពឹងផ្អែកទៅលើការស្រាវជ្រាវ និងការអភិវឌ្ឍន៍ចុងក្រោយបង្អស់ក្នុងផ្នែកវេជ្ជសាស្ត្រ។**

“ខ្ញុំទទួលបានការវិភាគរោគវិនិច្ឆ័យខុសៗគ្នាពីគ្រូពេទ្យជាច្រើនផ្សេងគ្នា។ តើខ្ញុំគួរធ្វើដូចម្តេចទៅ?”



**ចូលទៅទទួលសេវាពីក្រុមអ្នកគ្រប់គ្រងពហុវិន័យ ដែលជាអ្នកផ្តល់ទស្សនៈជារួមចំពោះលក្ខខណ្ឌវេជ្ជសាស្ត្រ និងជម្រើសនៃការព្យាបាលរបស់អ្នក**

“គ្រូពេទ្យឆ្អឹងរបស់ខ្ញុំណែនាំការវះកាត់មកខ្ញុំ។ តើការវះកាត់គឺជាជម្រើសតែមួយគត់មែនទេ?”



**សន្តិភាពផ្លូវចិត្តចំពោះគម្រោងព្យាបាលនិងការបំភ្លឺទាក់ទងទៅនឹងជំហ៊ានបន្តបន្ទាប់នីមួយៗ**

“បេះដូងកូនស្រីរបស់ខ្ញុំដូចជាមិនស្រួលនោះទេ។ តើគ្រូពេទ្យបេះដូងណាដែលខ្ញុំអាចជឿជាក់បាន?”



**ការណែនាំពីក្រុមអ្នកជំនាញជាន់ខ្ពស់ពីសកលលោក។**

“ថ្មីៗនេះ ខ្ញុំបានឆ្លងកាត់ការព្យាបាលគីមីសាស្ត្រ។ តើខ្ញុំគួរតែធ្វើអ្វីទៅសម្រាប់ការរស់នៅជាប្រចាំ?”



**ចូលទៅជួបជាមួយនឹងគ្រូពេទ្យគ្រប់គ្រងករណីសម្រាប់ដំបូន្មាន និងគាំទ្រឥតដែនកំណត់។**

# តើ TELADOC HEALTH អាចធ្វើអ្វីខ្លះបានសម្រាប់អ្នក?

ជាមួយសេវាកម្មគ្រប់គ្រងករណីដ៏ទូលំទូលាយរបស់ **Teladoc Health** អ្នកអាចរំពឹងបាននូវគុណភាពខ្ពស់ និងជំនួយផ្ទាល់ខ្លួនដូចខាងក្រោម៖

| គោលដៅត្រឹមត្រូវ | សន្តិភាពផ្លូវចិត្ត | ការព្យាបាលដ៏សាកសម | ការតាមដាន |
|---|---|---|---|
| ធ្វើអោយរោគវិនិច្ឆ័យមានសុពលភាព និងព្រមព្រៀងគម្រោងព្យាបាល | ឆ្លើយរាល់ចម្ងល់កំឡុងពេលធ្វើការព្យាបាល | ស្វែករកគ្រូពេទ្យដែលសាកសមសម្រាប់ការព្យាបាលរបស់អ្នក | គាំទ្រជាបន្តបន្ទាប់ប្រសិនជាអ្នកត្រូវការ |
| ↑ | ↑ | ↑ | ↑ |
| **គាំទ្រការសម្រេចចិត្ត** | **ការរុករក** | **ការតស៊ូមតិ** | **តាមដាន** |

### គាំទ្រការសម្រេចចិត្ត

**យោបល់វេជ្ជសាស្ត្រអ្នកជំនាញ**

- **អ្នកឯកទេសជាន់ខ្ពស់ច្រើនជាង 50.000 នាក់** – ដែលនឹងជួយអ្នកយ៉ាងជិតដល់សម្រាប់ជំនួយវេជ្ជសាស្ត្រផ្ទាល់ខ្លួនចាប់តាំងពេលធ្វើរោគវិនិច្ឆ័យរហូតដល់ពេលជាព្យាបាលក្នុងលក្ខខណ្ឌវេជ្ជសាស្ត្រសភាពធ្ងន់ធ្ងរ
- **ការពិនិត្យពហុវិន័យ** – អ្នកនឹងទទួលបានការគ្រប់គ្រងករណីពីដើមដល់ចប់ដែលនឹងត្រូវបានពិនិត្យមើលដោយក្រុមអ្នកគ្រប់គ្រងពហុវិន័យ និងអ្នកពហុជំនាញឯករាជ្យ
- **របាយការណ៍ទូលំទូលាយ** ដែលនឹងអនុញ្ញាតអោយអ្នកស្វែងយល់ពីករណីរបស់អ្នកយ៉ាងលម្អិតជាមួយនឹងគំនិតយោបល់ និងការណែនាំ ដែលជួយអោយអ្នកអាចធ្វើការសម្រេចចិត្តទៅលើវេជ្ជសាស្ត្របានយ៉ាងត្រឹមត្រូវ

### ការរុករក

**ការថែទាំវេជ្ជសាស្ត្រ**

- **ការផ្គូរផ្គងជំងឺទៅគ្រូពេទ្យព្យាបាល 2នាក់** – អ្នកនឹងមានគ្រូពេទ្យដែលសាកសមសម្រាប់ការព្យាបាលដ៏សមរម្យ
- **ការណែនាំ និងការណាត់ជួប** – មានការជួយសម្រួលសម្រាប់ទាក់ទងណាត់ជួបជាមួយគ្រូពេទ្យរបស់អ្នកនៅពេលដែលចាំបាច់
- **ការសង្ខេបខ្លឹមសារវេជ្ជសាស្ត្រជាមួយនឹងគ្រូពេទ្យព្យាបាល** – មានជំនួយក្នុងការពន្យល់ករណីវេជ្ជសាស្ត្រសង្ខេបរបស់អ្នកទៅគ្រូពេទ្យព្យាបាលជំងឺ

### ការតស៊ូមតិ

**ការតាមដាន**

- **ចូលជួបជាមួយនឹងគ្រូពេទ្យគ្រប់គ្រងករណីក្នុងស្រុកឥតដែនកំណត់** – អ្នកតែងតែអាចស្វែងរកអ្នកគ្រប់គ្រងករណីផ្ទាល់ខ្លួនរបស់អ្នកដើម្បីបកស្រាយចំងល់ និងរាល់សំណួរដែលមានក្នុងកំឡុងពេលព្យាបាល
- **មតិរបស់អ្នកជំងឺ** – អ្នកនឹងត្រូវបានស្តាប់ និងផ្តល់ចំលើយទាក់ទងនឹងពាក្យបច្ចេកទេសវេជ្ជសាស្ត្រ ដំណើរការ និងការពន្យល់ផ្សេងៗដោយអ្នកគ្រប់គ្រងករណីរបស់អ្នក

### តាមដាន

**ជំនួយជាបន្តបន្ទាប់**

- **តាមដានស្ថានភាពព្យាបាល** – តាមដានជាប្រចាំក្នុងដំណើរការព្យាបាលរបស់អ្នក និងធ្វើអោយប្រាកដថាអ្នកកំពុងស្តារទឹកចិត្ត និងភាពជឿជាក់របស់អ្នកឡើងវិញ
- **តែងតែពិនិត្យមើលថាមានតំរូវការអ្វីដែលចាំបាច់ឬអត់** – ពួកយើងធ្វើអោយប្រាកដថាអ្នកតែងតែត្រូវបានស្វាគមន៍រាល់ជំនួយទាំងអស់ដែលអ្នកត្រូវការ

ជំនួយការថែទាំវេជ្ជសាស្រ្ត
ប្រសិនជាចាំបាច់

ការអនុវត្តយ៉ាងសកម្ម និង
គ្រូពេទ្យគ្រប់គ្រងករណីដែល
មានសញ្ញាប័ត្រក្នុងស្រុក

ការតាមដាន និងគាំទ្រ
ជាបន្តបន្ទាប់ប្រសិនជាអ្នក
ត្រូវការ

អ្នកនឹងកំណត់អោយទទួលបានក្រុមអ្នកវេជ្ជសាស្រ្ត ដែលដឹកនាំដោយគ្រូពេទ្យគ្រប់គ្រងករណីដែលជាអ្នកនឹងផ្តល់
ដំបូន្មានវេជ្ជសាស្រ្ត ការណែនាំ និងការគាំទ្រជាប្រចាំសម្រាប់រយៈពេលឥតដែនកំណត់។

# របៀបប្រើប្រាស់សេវាកម្មនេះ

ទាក់ទងមកផ្នែកអតិថិជនរបស់ AIA Cambodia តាមរយៈ 086 999 242 ដើម្បីបញ្ជាក់ពីសិទ្ធទទួលបានសេវារបស់អ្នក

ផ្ញើទម្រង់បែបបទដែលបំពេញរួចជាមួយនឹងហត្ថលេខារបស់អ្នកទៅ AIA Cambodia

បន្ទាប់ពីទទួលបានបែបបទ Teladoc Healthនឹងកំណត់គ្រូពេទ្យគ្រប់គ្រងករណីដែលនិយាយភាសាអង់គ្លេសអោយទៅអ្នក និងណែនាំអ្នកនូវដំណើរការទាំងស្រុងនៃការគ្រប់គ្រងការថែទាំផ្ទាល់ខ្លួន។

គ្រូពេទ្យគ្រប់គ្រងករណីរបស់អ្នកនឹងទាក់ទងទៅអ្នកក្នុងរយៈពេល 24ម៉ោង ដើម្បីស្វែងយល់ និងពិនិត្យប្រវត្តិជំងឺរបស់អ្នក។

គណៈកម្មការវេជ្ជសាស្ត្រជ្រើសរើសអ្នកជំនាញជាន់ខ្ពស់ក្នុងលក្ខខណ្ឌជំងឺរបស់អ្នកដើម្បីពិនិត្យករណី។

ក្នុងរយៈ 10ថ្ងៃនៃថ្ងៃធ្វើការ អ្នកនឹងទទួលបានរបាយការណ៍ផ្ទាល់ខ្លួនយ៉ាងលម្អិតមួយជាមួយនឹងគំនិត និងការណែនាំដែលពន្យល់ដោយគ្រូពេទ្យគ្រប់គ្រងករណីរបស់អ្នក។

ប្រសិនអ្នកចង់បានការព្យាបាលក្រៅប្រទេស ឬអ្នកមិនពេញចិត្តជាមួយនឹងគ្រូពេទ្យបច្ចុប្បន្ន គ្រូពេទ្យគ្រប់គ្រងករណីរបស់អ្នកនឹងណែនាំអ្នកនូវអ្នកជំនាញ 2រូបផ្សេងទៀតនៅប្រទេសសិង្ហបុរី និងអ្នកអាចជ្រើសរើសពីជម្រើសទាំង 2នេះ

គ្រូពេទ្យគ្រប់គ្រងករណីរបស់អ្នកនឹងធ្វើការខលតាមដានដើម្បីអោយប្រាកដថាអ្នកទទួលបានការព្យាបាលត្រឹមត្រូវនិងជាសះស្បើយតាមផែនការ។ ការខលតាមដាននឹងត្រូវបានបញ្ចប់នៅពេលអ្នកស្នើរសុំប៉ុណ្ណោះ។

# តើអ្នកណានឹងទទួលបានអត្ថប្រយោជន៍ពីសេវាគ្រប់គ្រង និងការប្រឹក្សាព្យាបាលផ្ទាល់ខ្លួន?

សេវាកម្មបន្ថែមនេះនឹងផ្តល់ជូនតែអតិថិជនដែលមានធានារ៉ាប់រងស្រេចតែប៉ុណ្ណោះ ដែលជាអតិថិជនមានគោលនយោបាយជាធរមាននៃករណីដែលបើក ឬករណីបន្ថែមជាមួយនឹងអត្ថប្រយោជន៍សម្រាប់ការព្យាបាលជំងឺ ឬអត្ថប្រយោជន៍នៃជំងឺធ្ងន់ធ្ងរដែលមានទឹកប្រាក់សរុប **20.000** ដុល្លារសហរដ្ឋអាមេរិក ឬលើសពីនេះ

*សូមស្វែងរកសិទ្ធដែលអាចទទួលបានលក្ខខណ្ឌវេជ្ជសាស្ត្រក្នុងទំព័រទី6*

## ទំនាក់ទំនងមក **AIA Cambodia**

- ទាក់ទងមកអ្នករៀបចំគម្រោងជីវិត **AIA**
- ទាក់ទងមកសេវាកម្មអតិថិជនរបស់ **AIA**
- លេខទូរសព្ទ **086 999 242**
- តេលេក្រាម៖ **AIACambodia**
- ធ្វើការពីថ្ងៃច័ន្ទ ដល់ថ្ងៃសុក្រ ចាប់ពីម៉ោង 8ព្រឹក ដល់ 10យប់ រួមទាំងថ្ងៃបុណ្យជាតិ
- អាចនិយាយភាសាអង់គ្លេសបាន

# លក្ខខណ្ឌវេជ្ជសាស្ត្រដែលអាចមានសិទ្ធទទួលសេវាគ្រប់គ្រង និងការប្រើក្សាព្យាបាលផ្ទាល់ខ្លួន

1.ស្ថានភាពវេជ្ជសាស្ត្រដែលមិនមានរោគវិនិច្ឆ័យ
2.ជំងឺមហារីក
3.ជំងឺប្រពន្ធ័សរសៃប្រសាទ
4.ជំងឺត្រចៀក ច្រមុះ និងបំពង់ក (ENT)
5.ជំងឺភ្នែក
6.ជំងឺសរសៃឈាមបេះដូង
7.ជំងឺផ្លូវដង្ហើម
8.ជំងឺក្រពះពោះវៀន
9.ជំងឺថ្លើម
10.ជំងឺតម្រងនោម
11.ជំងឺប្រពន្ធ័ទឹកនោម
12.ជំងឺក្រពេញអង់ដូគ្រីន
13.ជំងឺឆ្អឹង
14.ជំងឺនៃឈាម
15.ជំងឺមេតាប៉ូលីស
16.ជំងឺប្រព័ន្ធភាពសាំុ
17.ជំងឺឆ្លង រួមទាំងមេរោគអេដស៍/ជំងឺអេដស៍
18.វះកាត់ព្យាបាលការស្រេមុក និងការគេងបាត់ដង្ហើម
19.ការវះកាត់កែសម្ផស្ស
20.លក្ខខណ្ឌឬនីតិវិធីទាក់ទងនឹងការមានកូន
21.លក្ខខណ្ឌសម្ភព
22.ជំងឺផ្លូវភេទ/ជំងឺកាមរោគ
23.ពេទ្យកុមារ
24.ជំងឺធាត់
25.ការជាសះស្បើយ/ការស្តារនិតិសម្បទាឡើងវិញនៃជំងឺដាច់សរសៃឈាមខួរក្បាល
26.ការជាសះស្បើយ/ ការស្តារនិតិសម្បទាឡើងវិញនៃជំងឺដាច់សរសៃឈាមខួរក្បាល
27.លក្ខខណ្ឌវេជ្ជសាស្ត្រក្នុងវិស័យទន្តសាស្ត្រ
28.ជំងឺរួមបញ្ចូលគ្នា
29.និងរាល់លក្ខខណ្ឌវេជ្ជសាស្ត្រទាំងអស់ក្រៅពីលក្ខខណ្ឌដែលមាននៅក្នុងបញ្ជីដកចេញខាងក្រោម

## លក្ខខណ្ឌវេជ្ជសាស្ត្រដែលមិនរាប់បញ្ចូល

អតិថិជនដែលបានធ្វើរោគវិនិច្ឆ័យជាមួយនឹងលក្ខខណ្ឌវេជ្ជសាស្ត្រខាងក្រោមគឺមិនមានសិទ្ធសម្រាប់សេវាកម្មនោះទេ៖

**សង្គ្រោះបន្ទាន់**

1. គ្រោះថ្នាក់
2. ស្ថានភាពបន្ទាន់ ឬកំពុងគំរាមកំហែងជីវិត
3. បញ្ហាប្រចាំថ្ងៃឬធម្មតាដូចជា គ្រុនផ្តាសសាយ ក្តៅខ្លួន ឬកន្ទួលរមាស់ម្តងម្កាល
4. ជំងឺរ៉ាំរ៉ៃដូចជាជំងឺទឹកនោមផ្អែម ឡើងឈាម ឡើងជាតិខ្លាញ់ និងរលាកខ្លាញ់រ៉ាំរ៉ៃ
5. លក្ខខណ្ឌសុខភាពផ្លូវចិត្តដូចជាជំងឺអត់ឃ្លានអាហារ សរសៃប្រសាទ សតិអារម្មណ៍មិននឹងនរ និងជំងឺភ័យខ្លាច

**ចំណាំ៖**

• សម្រាប់លក្ខខណ្ឌវេជ្ជសាស្ត្រដោយគ្មានការវិភាគរោគវិនិច្ឆ័យ អតិថិជនចាំបាច់ត្រូវតែមានការអង្កេតវេជ្ជសាស្ត្រ និងការណែនាំជាមួយនឹងគ្រូពេទ្យនៅក្នុងវិស័យវេជ្ជសាស្ត្រយ៉ោងហោចណាស់មួយ។
• ភាពស្មុគស្មាញនៃជំងឺរ៉ាំរ៉ៃគឺមានសិទ្ធទទួលសេវាគ្រប់គ្រង និងការប្រឹក្សាព្យាបាលផ្ទាល់ខ្លួន

# អំពី TELADOC HEALTH

Teladoc Health គឺជាអ្នកនាំមុខនៅក្នុងវិស័យសេវាកម្មថែទាំបែបអនឡាញជាមួយនឹងអាយុកាលជាង 20ឆ្នាំក្នុងការបម្រើសេវាកម្មជូនអតិថិជនរាប់លាននាក់នៅអាស៊ី និងទូទាំងពិភពលោក។




បណ្ដាញអ្នកជំនាញកំពូលជាង **50.000+** ពីសកលលោក

គ្រប់ដណ្ដប់ដោយអ្នកឯកទេសរងជាង **450+**

បានបម្រើសេវាកម្មច្រើនជាង **175** ប្រទេស

និយាយបានជាង **40+** ភាសា

មនុស្សច្រើនជាង **92+** លាននាក់ អាចចូលទៅកាន់សេវាកម្មឬផលិតផលរបស់ Teladoc Health

ពិន្ទុនៃការពេញចិត្តពីអតិថិជនគឺ **98%**

ឈ្នះពានរង្វាន់ JD Power ក្នុងឆ្នាំ **2021**

សុខភាព និងជីវិត
កាន់តែប្រសើរ

**ការិយាល័យកណ្តាល**

អគារ ជីអាយអេ ថៅអឺរ ជាន់ទី31 ផ្លូវសុភមង្គល ភូមិ14 សង្កាត់ទន្លេបាសាក់
ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

**សាខាសៀមរាប**

អគារលេខ 29 និង 30
ផ្លូវហ្សាលដឺហ្គោល សាលាកន្សែង សង្កាត់ស្វាយដង្គំ
ទីរួមខេត្តសៀមរាប

**សាខាបាត់ដំបង**

ផ្ទះលេខ 2-6ផ្លូវលេខ 3 ភូមិកម្មករ សង្កាត់ស្វាយប៉ោ
ក្រុងបាត់ដំបង ខេត្តបាត់ដំបង

**សាខាកំពង់ចាម**

ភូមិ 15 សង្កាត់កំពង់ចាម ខណ្ឌកំពង់ចាម ខេត្តកំពង់ចាម

**សាខាកំពត**

ផ្លូវលេខ 700 ភូមិ 1ឧសភា សង្កាត់កំពង់កណ្តាល
ក្រុងកំពត ខេត្តកំពត

ខិត្តប័ណ្ណនេះមិនមែនជាកិច្ចសន្យាធានារ៉ាប់រងទេ គឺសម្រាប់តែព័ត៌មានប៉ុណ្ណោះ។ Teladoc Health គឺជាក្រុមហ៊ុនឯករាជ្យភាគីទីបី។ AIA នឹងមិនទទួលខុសត្រូវចំពោះសេវាកម្មវេជ្ជសាស្រ្ត ផលិតផល ឬការខិតខំប្រឹងប្រែងការស្នើរសុំដែលផ្តល់ដោយ Teladoc Health ដែលមិនត្រូវបានដាក់លក់ ឬក៏ធ្វើទីផ្សារដោយ AIA ឡើយ។
សូមចូលទៅកាន់គេហទំព័រ https://www.aia.com.sg/ សម្រាប់បញ្ជីករណីវេជ្ជសាស្រ្តធ្ងន់ធ្ងរទាំងអស់ដែល Teladoc Health ព្រមទទួលសម្រាប់ការគ្រប់គ្រងករណីផ្ទាល់ខ្លួន។ សិទ្ធទទួលបានសេវាកម្មគឺអាស្រ័យទៅការវាយតម្លៃដោយ AIA និង Teladoc Health ហើយសេវាកម្មដែលបានផ្តល់អោយគឺអាស្រ័យទៅលើលក្ខខណ្ឌនៃ Teladoc Health។ សូមទាក់ទង Teladoc Health សម្រាប់ព័ត៌មានលម្អិតពេញលេញនៃវិសាលភាពនៃសេវាកម្ម។

គម្រោងធានារ៉ាប់រងត្រូវបានសរសេរចេញដោយ AIA (Cambodia) Life Insurance Plc.។ រាល់លិខិតស្នើរសុំធានារ៉ាប់រងទាំងអស់គឺអាស្រ័យទៅលើការសរសេរចេញ និងយល់ព្រមពី AIA។ វាមិនមែនជាធានារ៉ាប់រងកិច្ចសន្យានោះទេ។ អ្នកត្រូវបានណែនាំអោយអានកិច្ចសន្យាគោលនយោបាយ សម្រាប់អោយយល់ពីលក្ខខណ្ឌនៃគម្រោងកាន់តែច្បាស់។

ព័ត៌មានត្រូវបានកែសម្រួលនៅថ្ងៃទី1 ខែកក្កដា ឆ្នាំ2022